ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថា

## លោកជំទាវ ជា សិរី អគ្គនាយករបច្ចេកទេស ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទសិក្ខាសាលាស្តីពី សារៈសំខាន់នៃការចងក្រងស្ថិតិ

សណ្ឋាគារភ្នំពេញ ថ្ងៃសុក្រ ៦កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨

**សូមគោរព**!

– គណៈអធិបតី

– ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

សិក្ខាសាលាស្តីពីសារៈសំខាន់នៃការចងក្រងស្ថិតិ រយៈពេលពេញមួយថ្ងៃនេះបានឈានដល់ទីបញ្ចប់ ប្រកបដោយជោគជ័យនិងផ្លែផ្កាដ៏ល្អប្រសើរ ។ ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងសិក្ខាសាលានេះ ដើម្បីស្វែងយល់ពីដំណើរការនៃការចងក្រងស្ថិតិម៉ាក្រូសេដ្ឋកិច្ច និងការប្រើប្រាស់ស្ថិតិទាំងនេះក្នុងគោលដៅផ្សេងៗក្នុងវិស័យសេដ្ឋកិច្ច ។

ខ្ញុំសូមបញ្ជាក់ថា ដើម្បីអាចប្រើប្រាស់ផលិតផលចុងក្រោយនៃស្ថិតិក្នុងគោលបំណងនានា ការផលិតស្ថិតិត្រូវបានឆ្លងកាត់ជាច្រើនដំណាក់កាលដូចជា ការប្រមូល ការចងក្រង ការវិភាគ ការបកស្រាយ ការរៀបចំ និងការផ្សព្វផ្សាយជាដើម ។ ក្នុងយុគសម័យនៃបច្ចេកវិទ្យា និងវិទ្យាសាស្ត្រទំនើប ស្ថិតិដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានចាំបាច់ ដើម្បីជំរុញ និងលើកកម្ពស់ការវិភាគឲ្យបានគ្រប់ជ្រុងជ្រោយ និងការធ្វើសេចក្តីសម្រេចចិត្តនានាទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន ។ ពាក់ព័ន្ធនឹងស្ថិតិនេះ លោក Jonathan Rosenberg ជាទីប្រឹក្សាសាជីវកម្ម Alphabet ដែលជាក្រុមហ៊ុនមេរបស់ក្រុមហ៊ុន Google បានលើកឡើងថា "statistics is the sword of the 21st century, those who wield it well, the Samurai" មានន័យថា

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ស្ថិតិ ប្រៀបដូចជាដាវក្នុងសតវត្សទី២១នេះ ប្រសិនបើប្រើប្រាស់បានល្អ វានឹងក្លាយជាអាវុធដ៏មុតស្រួចបំផុត ដូចដាវសាំមូរ៉ៃ ។ ហេតុដូច្នេះ ស្ថិតិមិនត្រឹមតែជាតួលេខធម្មតាប៉ុណ្ណោះទេ តែវាថែមទាំងបានដើរតួនាទីមិនអាចខ្វះបាន និងជាគ្រឿងផ្សំដ៏ចាំបាច់ក្នុងការរៀបចំ ការត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់លើផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ប្រទេស ក្នុងគោលដៅចុងក្រោយដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋផងដែរ ដូចបានលើកឡើងដោយវាគ្មិនក្នុងថ្ងៃនេះអំពីសារៈសំខាន់របស់ស្ថិតិក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ការរៀបចំផែនការថវិកាជាតិ និងការតាមដាននិងវាយតម្លៃដំណើរការសេដ្ឋកិច្ចរបស់កម្ពុជា ។

ជាមួយគ្នានេះ ស្ថិតក្នុងបរិបទនៃសាកលភាវូបនីយកម្ម ដែលសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្នកាន់តែមានភាពប្រទាក់ក្រឡា និងសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់ និងពិភពលោក តម្រូវការស្ថិតិក៏មានភាពចាំបាច់ផងដែរ សម្រាប់ការវិភាគ និងការប្រៀបធៀបលទ្ធភាពប្រកួតប្រជែងសេដ្ឋកិច្ចអន្តរជាតិ ការចរចាពាណិជ្ជកម្មអន្តរជាតិផ្នែកទំនិញនិងសេវាកម្ម និងសមាហរណកម្មប្រព័ន្ធស្ថិតិក្នុងតំបន់ ។ ជាក់ស្តែង សមាគមសេដ្ឋកិច្ចអាស៊ានដែលបានបង្កើតក្នុងឆ្នាំ២០១៥ មានគោលដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នយោបាយ សង្គម និងវប្បធម៌ក្នុងតំបន់ និងប្រែក្លាយតំបន់អាស៊ានជាមូលដ្ឋានផលិតកម្ម និងជាទីផ្សាររួមសម្រាប់ការប្រកួតប្រជែងក្នុងពិភពលោក ជាមួយនឹងលំហូរដោយសេរីនូវទំនិញ សេវាកម្ម ពលកម្ម និងការវិនិយោគក្នុងចំណោមប្រទេសទាំង១០ ។ ក្នុងផែនការនេះ ផ្នែកសំខាន់មួយនៃដំណើរការដើម្បីសម្រេចឲ្យបាននូវគោលដៅសមាហរណកម្មសេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ គឺការធ្វើសមាហរណកម្មប្រព័ន្ធស្ថិតិ ដែលតម្រូវឲ្យប្រទេសជាសមាជិកត្រូវធ្វើបច្ចុប្បន្នកម្មវិធីសាស្ត្រចងក្រងស្ថិតិ និងមានភាពលម្អិត ដើម្បីងាយក្នុងការធ្វើគោលនយោបាយរួម និងស្វែងយល់ពីតម្រូវការរបស់ប្រទេសនីមួយៗ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!

ដើម្បីសម្រេចបាននូវគោលនយោបាយដូចរៀបរាប់ខាងលើប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ទិន្នន័យដែលមានគុណភាព និងទាន់ពេលវេលា ចាំបាច់ត្រូវប្រើប្រាស់ជាធាតុចូលដ៏សំខាន់ ដើម្បីរៀបចំគោលនយោបាយ និងផែនទីវិថីសម្រាប់ការអនុវត្តជាជំហានៗ ព្រមទាំងជាសូចនាករសម្រាប់បំភ្លឺផ្លូវលើដំណើរឆ្ពោះទៅកាន់គោលដៅនីមួយៗដែលបានគ្រោងទុក ។ ចំពោះការប្រមូល និងការចងក្រងស្ថិតិផ្លូវការនៅកម្ពុជា បើទោះជាមានច្បាប់ស្តីពីស្ថិតិសម្រាប់ទ្រទ្រង់សកម្មភាពទាំងនេះក្តី ការផលិតស្ថិតិប្រកបដោយគុណភាព និងទាន់ពេលវេលានៅតែជាបញ្ហាប្រឈមរបស់ក្រសួងស្ថាប័នចងក្រងស្ថិតិ ដោយសារកង្វះកិច្ចសហការល្អលើការចែករំលែកទិន្នន័យ ទាំងវិស័យសាធារណៈនិងឯកជន ព្រមទាំងការយល់ដឹងពីសារៈសំខាន់នៃតួនាទីស្ថិតិក្នុងដំណើរការធ្វើសេចក្តីសម្រេចនានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ហេតុដូចនេះ ខ្ញុំសង្ឃឹមយ៉ាង

មុតមាំថា សិក្ខាសាលាថ្ងៃនេះ បានផ្តល់ជូនជាគតិ និងទស្សនាទានសំខាន់មួយចំនួនអំពីភាពចាំបាច់របស់ស្ថិតិ ហើយរំពឹងថា សិក្ខាកាមមកពីក្រសួងស្ថាប័ននីមួយៗ នឹងចូលរួមលើកកម្ពស់ការចែករំលែកទិន្នន័យដល់ក្រសួងស្ថាប័នចងក្រងស្ថិតិផ្លូវការ ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិ ក្នុងគោលបំណងផលិតស្ថិតិដែលមានគុណភាពខ្ពស់និងវិសាលភាពទូលំទូលាយ ដើម្បីប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ផែនការនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការសិក្សាស្រាវជ្រាវនានា ដែលពាក់ព័ន្ធនឹងប្រធានបទសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងវិស័យឯកជនមួយចំនួន ដែលតែងតែសហការផ្តល់ទិន្នន័យជាប្រចាំដល់ធនាគារជាតិនៃកម្ពុជា ដើម្បីផលិតស្ថិតិម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ស្ថិតិជញ្ជីងទូទាត់ និងស្ថិតិរូបិយវត្ថុ សម្រាប់បម្រើដល់ការវិភាគ និងការរៀបចំគោលនយោបាយរូបិយវត្ថុ ស្ថេរភាពហិរញ្ញវត្ថុ និងបទបញ្ញត្តិប្រុងប្រយ័ត្នសម្រាប់ប្រព័ន្ធធនាគារនាពេលកន្លងមក ។ ខ្ញុំក៏សូមកោតសរសើរ និងថ្លែងអំណរគុណចំពោះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដែលតែងតែចូលរួមសហការគាំទ្រក្នុងកិច្ចការ ពង្រឹងគុណភាព និងវិសាលភាពស្ថិតិ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ឱ្យជួបប្រទះតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបិទសិក្ខាសាលាស្តីពី សារៈសំខាន់នៃការចងក្រងស្ថិតិ ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**!